# សេចក្ដីបង្រៀន
# របស់លោកដេរេក ព្រីនស៍

DEREK PRINCE

MINISTRIES ASIA-PACIFIC

## <u>ការឈរនៅចន្លោះ</u>

*ដូច្នេះ ខ្ញុំទូន្មានសេចក្ដីនេះជាមុនដំបូងថា ចូរពោលពាក្យអរព្រះគុណ ពាក្យទូលសូម ពាក្យអធិស្ឋាន និងពាក្យទូលអង្វរឲ្យមនុស្សទាំងអស់ ។*

**១ធីម៉ូថេ ២: ១**

លោកប៉ូល បានប្រាប់យើងថា អាទិភាពដំបូងនៃការជួបប្រជុំរបស់គ្រីស្ទាន គឺ**ជាការអធិស្ឋាន**ដែលក្នុងនោះមានទ្រង់ជាអ្នកទូលអង្វរ ។

ពាក្យថា៖ " **អង្វរជំនួស** " វាមានន័យចំថា( **ចូលមកក្នុងរវាង** ) ។ អ្នកទូលអង្វរជំនួស គឺជាម្នាក់ដែលមករវាងព្រះ និង អ្នកដែលសាកសមនឹងទទួលសេចក្ដីក្រោធ និង ការជំនុំជំរះរបស់ទ្រង់។ពួកគេបានលើកដៃរបស់ពួកគេចំពោះព្រះ ហើយបាននិយាយថា សូមទ្រង់វិនិច្ឆ័យទោសមនុស្សតាមការដែលគេសមនឹងទទួលបាន ។

ហើយទ្រង់ក៏មានគ្រប់ទាំងសិទ្ធអំណាច ក្នុងការវិនិច្ឆ័យទោសដែរ ប៉ុន្តែបើសិនជាទ្រង់ដាក់ទោសគេ សូមទ្រង់ដាក់ទោសដល់ទូលបង្គំមុនសិន ពីព្រោះទូលបង្គំ ជាអ្នកដែលឈររវាងទ្រង់ ហើយនឹងពួកគេ ។ នៅក្នុងសញ្ញាចាស់យើងអាចរកឃើញនូវករណីជាច្រើនរបស់ទីក្រុង និង ប្រជាជាតិដែលបានរួចពីការជំនុំជំរះរបស់ព្រះជាម្ចាស់ តាមរយៈការងារបេសកកម្មរបស់អ្នកទូលអង្វរជំនួស ។

យើងនឹងរៀនចេញពីឧទាហរណ៍ខ្លះៗទាំងនេះ ៖ សូមអោយយើងបានពិចារណាអំពី ការងារបេសកកម្មក្នុងការទូលអង្វររបស់ព្រះអម្ចាស់យេស៊ូគ្រីស្ទ ជាព្រះនៃយើងជាមុនដំបូងសិន ។

## *ការទូលអង្វរនៅក្នុងជីវិតព្រះយេស៊ូគ្រីស្ទ*

ការទូលអង្វរ ជាផ្នែកមួយនៃសញ្ញាដ៏អស្ចារ្យ ក្នុងការងារបេសកកម្មរបស់ព្រះយេស៊ូ ។ កំណ្ឌព្រះគម្ពីរ **អេសាយ ៥៣** ផ្តល់នូវការពិពណ៌នាពីការងារដែលធ្វើអោយធួនរបស់លោក ដោយបានបញ្ចប់នៅក្នុង**ខ ១២** ៖

**<u>អេសាយ ៥៣៖ ១២</u>** *ហេតុនោះអញនឹងឲ្យទ្រង់មានចំណែកជាមួយនឹងពួកអ្នកធំ ហើយទ្រង់នឹងចែករបឹប*

*ជាមួយនឹងពួកអ្នកដ៏ខ្លាំងពូកែ ពីព្រោះទ្រង់បានច្រូចព្រលឹងចេញ រហូតដល់ស្លាប់ គេបានរាប់ទ្រង់ទុកជាអ្នកទទឹងច្បាប់ ប៉ុន្តែទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើន* ***ហើយបានអង្វរជំនួសមនុស្សដែលទទឹងច្បាប់វិញ ។***

**<u>មានការ ៤ យ៉ាងដែលបានកត់ទុកអំពីព្រះយេស៊ូនៅត្រង់ខនេះ ៖</u>**

**<u>ទី ១៖</u>** ទ្រង់បានច្រូចព្រលឹងចេញរហូតដល់ស្លាប់ ។

**លេវីវិន័យ ១៧៖១១** *បាននិយាយថា ព្រលឹងនៃរូបសាច់នោះនៅក្នុងឈាម ហើយទ្រង់បានច្រូចព្រលឹងចេញរហូតដល់ស្លាប់ នៅពេលដែលទ្រង់បានច្រូចឈាមរបស់ទ្រង់ចេញ ។*

**<u>ទី២៖</u>** ទ្រង់ត្រូវបានគេ រាប់បញ្ចូលជាមួយមនុស្សអាក្រក់ ទ្រង់ត្រូវគេឆ្កាងជាអ្នកទី បី ជាមួយនឹងចោរ ។

**<u>ទី៣៖</u>** ទ្រង់បានទទួលរងទុក្ខយ៉ាងធ្ងន់ធ្ងរ សំរាប់មនុស្សជាច្រើន ទ្រង់ត្រលប់ទៅជាដង្វាយសំរាប់យើងទាំងអស់គ្នា ។

**<u>ទី ៤ ៖</u>** ទ្រង់បានទូលអង្វរសំរាប់អស់អ្នកដែលបានធ្វើបាប ហើយទ្រង់បានធ្វើសម្រេចការនេះនៅលើឈើឆ្កាង

នៅពេលដែលទ្រង់មានបន្ទូលថា « *ព្រះវរបិតាអើយ ! សូមអត់ទោសអោយពួកគេផងដ្បិតគេមិនដឹងថាគេកំពុងតែធ្វើអ្វីទេ* » ***លូកា ២៣៖ ៣៤***

ទ្រង់មានបន្ទូលថា « ការដែលត្រូវជំនុំជំរះលើកពួកគេនោះ សូមអោយធ្លាក់មកលើខ្ញុំចុះ » ខ្ញុំបានធ្វើការទាំងអស់នេះសំរាប់ពួកគេរួចរាល់ហើយ ។

**ហេព្រើរ ៧** បាននិយាយ អំពីការសុគតរបស់ព្រះយេស៊ូការរស់ឡើងវិញ និង ការយាងឡើងទៅស្ថានសួគ៏វិញ។ យើងអាចនិយាយបានថាព្រះយេស៊ូ គឺជាសម្តេចសង្ឃដែលនៅព្រះហស្តស្តាំរបស់ព្រះ។

ដោយព្រោះថា ទ្រង់មានភាពជាសម្តេចសង្ឃដែលមិនអាចផ្លាស់ប្តូរបាន នោះគ្មានណារម្នាក់អាចឆ្លង់ទៅឯព្រះបាន ដោយមិនបានឆ្លងកាត់ទ្រង់នោះឡើយ ។

« ***ដោយហេតុនោះបានជាទ្រង់អាចនឹង ជួយសង្គ្រោះសព្វគ្រប់បាន ដល់មនុស្សទាំងអស់ ដែលចូលទៅឯព្រះដោយសារទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ចដើម្បីនឹងជួយអង្វរជំនួសគេ*** » ***ហេព្រើរ ៧ ៖ ២៥***

ប្រសិនបើយើងបានធ្វើការសិក្សាពីជីវិត និងការបម្រើរបស់ព្រះយេស៊ូ។ យើងនឹងធ្វើការប្រៀបធៀបដ៏គួរឱ្យចាប់អារម្មណ៍ ។ ទ្រង់បានចំណាយពេល ៣០ ឆ្នាំក្នុងការរស់នៅយ៉ាងស្ងប់ស្ងាត់ជាមួយក្រុមគ្រួសារ ដែលល្អ

ឥតខ្ចោះ។ហើយទ្រង់បានចំណាយពេល ៣ ឆ្នាំកន្លះ សំរាប់ការងារផ្សាយដំណឹងល្អយ៉ាងខ្លាំង នឹងជាង ២០០០ ឆ្នាំមកហើយដែលទ្រង់ដើរតួរជាអ្នកទូលអង្វរ ដែលយើងមិនអាចមើលឃើញដោយភ្នែក។ ចាប់តាំងពីទ្រង់បានឡើងទៅធ្វើជាអ្នកទូលអង្វរជំនួសយើង នៅចំពោះព្រះវរបិតា ។

## *គំរូពីលោកអ័ប្រាហាំ ក្នុងព្រះគម្ពីរសញ្ញាចាស់*

ប្រជាជនដ៏បរិសុទ្ធ ដ៏អស្ចារ្យបំផុត គឺជាអ្នកទូលអង្វរ ដ៏ធំបំផុត ដែលជាញឹកញាប់សម្រាប់ពួកគេជាមនុស្ស ដែលនៅជិតនឹងព្រះហឫទ័យ របស់ព្រះជាម្ចាស់។

នៅក្នុងគ្រាសញ្ញាចាស់ មានឧទាហរណ៍នៃការដ៏អស្ចារ្យមួយចំនួនចំពោះការងារជាអ្នកអង្វរជំនួស៕

នៅក្នុង**ព្រះគម្ពីរលោកុប្បត្តិ ជំពូកទី ១៨** យើងបានឃើញព្រះជាម្ចាស់ បានយាងមកជាមួយនឹងទេវតារបស់ទ្រង់ទាំង ពីរ មកសួរសុខទុក្ខលោកអាប្រាហាំនៅត្រង់ទីជំឡើងត្រសាលរបស់លោក។ មុនពេលដែលទ្រង់ត្រឡប់ទៅវិញ ទ្រង់បានមានបន្ទូលនឹងទេវតាដែលបានមកជាមួយទ្រង់ថា៖ « តើត្រូវលាក់នឹងអ័ប្រាហាំពីការដែលអញរៀបនឹងធ្វើឬទេ » **ខ ១៧** ។

នៅក្នុងអត្ថបទព្រះគម្ពីរផ្សេងទៀតបានប្រាប់ថា ព្រះបានចាត់ទុកលោកអ័ប្រាហាំ ដូចជាមិត្តចិត្តស្និទ្ធដែល

ទ្រង់អាចនឹងចែកចាយពីអ្វីដែលទ្រង់បានគិត និងអ្វីដែលជាផែនការរបស់ទ្រង់ដែលត្រូវធ្វើ ។

ដូច្នេះហើយ ព្រះទ្រង់បានប្រាប់ទៅលោកអ័ប្រាហាំថា៖

*« ២០. រួចព្រះយេហូវ៉ាទ្រង់មាន ព្រះបន្ទូលថា ពីព្រោះសំរែកនៃក្រុងសូដុម នឹងក្រុងកូម៉ូរ៉ាបានឮជាខ្លាំង ហើយអំពើបាបរបស់គេក៏ធ្ងន់ណាស់ផង* ***២១.*** *នោះបានជាអញចុះទៅមើលឥឡូវ ដើម្បីឲ្យដឹង បើគេបានប្រព្រឹត្តដូចជាសំរែកដែលអញបានឮនោះឬទេ បើមិនមែនទេ នោះអញនឹងបានដឹង»* ***( លោកុប្បត្តិ ១៨ )***

អ័ប្រាហាំមានការព្រួយបារម្មណ៍ជាខ្លាំង ចំពោះក្រុងសូដុម ពីព្រោះគាត់មានក្មួយប្រុសម្នាក់រស់នៅទីនោះគឺឡុត។ អ័ប្រាហាំដឹងថា នៅពេលដែលការជំនុំជំរះបានមកដល់លើក្រុងសូដុម នោះឡុត ហើយនិងគ្រួសាររបស់លោកក៏ត្រូវទទួលរងនូវការវិនាសដែរ ។

**ហេតុការណ៍នោះត្រូវតែកើតឡើង ៖**

*«****២២.*** *រួចក៏បែរចេញ (ទេវតា ) ពីនោះដំរង់ទៅខាងឯក្រុងសូដុមទៅ តែអ័ប្រាហាំគាត់ឈរនៅចំពោះព្រះយេហូវ៉ានៅឡើយ។* ***២៣.*** *អ័ប្រាហាំក៏ចូលទៅជិតទូលសួរថា តើទ្រង់នឹងបំផ្លាញមនុស្សសុចរិតជាមួយនឹងមនុស្ស*

*អាក្រក់ផងដែរឬអី ២៤. បើសិន ជាមានមនុស្សសុចរិត **៥០នាក់**នៅក្នុងក្រុងនោះ តើទ្រង់នឹងបំផ្លាញអស់រលីងទៅ ឥតមានប្រណីដល់ទីក្រុង ដោយព្រោះមនុស្សសុចរិត៥០នាក់ ដែលនៅទីនោះទេឬអី ២៥. មិន គួរគប្បីឲ្យទ្រង់ប្រព្រឹត្តដូច្នេះ និងសំឡាប់មនុស្សសុចរិតជាមួយនឹងមនុស្សអាក្រក់នោះទេ យ៉ាងនោះឈ្មោះថាធ្វើឲ្យមនុស្សសុចរិតបានដូចជាមនុស្សអាក្រក់ដែរ សូមកុំឲ្យទ្រង់ធ្វើដូច្នោះឡើយ ឯព្រះដ៏ជាចៅក្រមផែនដីទាំងមូល តើទ្រង់មិនត្រូវប្រព្រឹត្តដោយយុត្តិធម៌ទេឬអី ?*

***លោកុប្បត្តិ ១៨ ៖ ២២ - ២៥***

អ័ប្រាហាំពេញដោយភាពក្លាហាន ក្នុងការប្រើមធ្យោបាយនិយាយទៅកាន់ព្រះជាម្ចាស់ ។ អ័ប្រាហាំបានដឹងទាំងស្រុងអំពីព្រះហឫទ័យថៃរក្សា ជាមួយនិងនិស្ស័យរបស់ព្រះ ហើយផ្ទុយមកវិញគឺថាទ្រង់ជាព្រះដែលពេញដោយសេចក្តីយុត្តិធម៌ ទ្រង់មិនអាចអោយការដាក់ទោសនេះ ធ្លាក់ទៅលើមនុស្សសុចរិតឡើយ ។

**ទំនុកតំកើន ៩១ : ៧ – ៨ កំណាត់ចេញនូវគោលការនេះ**

*៧. នឹងមានមនុស្ស១ពាន់នាក់ដួលស្លាប់នៅក្បែរឯង ហើយ១ម៉ឺននាក់នៅខាងដៃស្តាំឯងដែរ តែសេចក្តីនោះនឹងមិនមកជិតឯងឡើយ ៨. ឯងនឹងបានក្រឡេកឃើញការតបស្នង ដល់ពួកមនុស្សអាក្រក់ ដោយភ្នែកតែប៉ុណ្ណោះទេ* ។ ការដាក់ទោសគឺសំរាប់តែមនុស្សអាក្រក់ប៉ុណ្ណោះ វាមិនអាចប៉ះពាល់ដល់មនុស្សសុចរិតឡើយ ។

មនុស្សសុចរិតប្រហែលអាចនៅក្នុងចំណោមនៃអ្នកដែលត្រូវជាប់ជំនុំជំរះ ប៉ុន្តែវានឹងមិនមានផលប៉ះពាល់ដល់អ្នកនោះឡើយ ។

__**ចំណាំ៖**__ ទោះយ៉ាងណាក៏ដោយវាមានភាពខុសគ្នារវាងការដាក់ទោស និង ការបៀតបៀន នោះគឺប្រយោជន៍អោយបានសុចរិត ។

ព្រះគម្ពីរបាននិយាយថា មនុស្សសុចរិតនឹងត្រូវទទួលបទពិសោធន៍ក្នុងការបៀតបៀន ។ ការខុសគ្នានោះគឺជា ការដាក់ទោសអំពើអាក្រក់ទៅលើមនុស្សអាក្រក់នោះគឺមកពីព្រះ ។

ប៉ុន្តែ ការបៀតបៀនចំពោះសេចក្តីសុចរិត មកលើមនុស្សសុចរិត គឺមកពីមនុស្សទុច្ចរិត ។

ដូច្នេះ ដោយមានចិត្តអង់អាចចំពោះការផ្តន្ទាទោសដ៏បរិសុទ្ធដែលព្រះទ្រង់នឹងដាក់ចេញនោះ លោកអ័ប្រា

ហាំបានកំណាត់ចេញដើម្បីប្រកួតប្រជែងជាមួយព្រះជាម្ចាស់លើគោលការណ៍ « ព្រះជាម្ចាស់ ប្រសិនបើនៅទីនេះមានមនុស្សសុចរិត **៥០ នាក់** នៅក្នុងទីក្រុងនេះ តើទ្រង់នឹងប្រណីដល់ទីក្រុងនេះឬទេ? នោះទ្រង់ឆ្លើយនឹងអ័ប្រាហាំថា យើងនឹងប្រណីដល់ទីក្រុងនេះ ប្រសិនជារកឃើញថាមានមនុស្សសុចរិត ៥០ នាក់នោះ ។

« ចុះបើមានតែ **៤៥នាក់** តើទ្រង់នឹងប្រណីដល់ទីក្រុងនេះ ដោយយល់ដល់មនុស្សសុចរិត ៤៥នាក់នេះទេ? ហើយព្រះទ្រង់មានបន្ទូលថា អញនឹងប្រណីដល់ទីក្រុងនេះដោយយល់ដល់មនុស្សសុចរិត ៤៥ នាក់នោះ ។

អ័ប្រាហាំក៏បន្តធ្វើការសន្ទនាជាមួយព្រះបន្តទៅទៀតគឺចាប់ពី **៤០ នាក់**, **៣០ នាក់**, **២០ នាក់** រហូតមកដល់ការសំរបសម្រួលចុងក្រោយរបស់លោក « ប្រហែលជាមានមនុស្សសុចរិតត្រឹមតែ **១០នាក់** ប៉ុណ្ណោះនៅក្នុងទីក្រុងទាំងមូល ដូច្នេះតើទ្រង់នឹងប្រណីដល់ទីក្រុងនេះដោយយល់ដល់មនុស្សសុចរិត ១០ នាក់ នេះឬទេ ៕

ហើយទ្រង់មានបន្ទូលថា អញនឹងប្រណីដល់ទីក្រុងនេះដោយយល់ដល់មនុស្សសុចរិត ១០ នាក់នោះ។

នេះគឺជាការបើកសំដែងមួយដ៏អស្ចារ្យ! ប្រសិនបើការគណនារបស់ខ្ញុំមិនខុសទេគឺមានប្រជាជនមិនតិចជាង ១០,០០០ នាក់ ឡើង ដែលរស់នៅទីក្រុងនោះ។

ដោយសារមនុស្សសុចរិត ១០នាក់ នោះព្រះមានប្រហាឬទ័យប្រណីដល់មនុស្ស ១០,០០០ នាក់ ។

មានន័យថា មនុស្ស ១ នាក់ អាចជួយសង្គ្រោះមនុស្ស១,០០០ នាក់បាន ។ មួយក្នុងចំណោម១ពាន់ព្រះគម្ពីរប្រើឃ្លានេះដាក់ស្តែងដើម្បីផ្តល់សញ្ញាខាងក្រៅជាបុរសនៃសេចក្តីសុចរិតដ៏ឆ្នើមមួយ។

**<u>ព្រះទ្រង់មានបន្ទូលថា</u>** « *ប្រសិនជាទ្រង់អាចនឹងរកឃើញថាមានមនុស្សសុចរិតតែម្នាក់ ក្នុងចំណោម មួយពាន់ នាក់ នោះទ្រង់នឹងប្រណីដល់ទីក្រុងនេះទាំងមូល* » ។

ប្រសិនបើយើងអនុវត្តតាមសមាមាត្រទៅនឹងទីក្រុងរបស់យើងផ្ទាល់ តើយើងនឹងមានលក្ខណៈគ្រប់គ្រាន់ ដែលជាផ្នែកមួយរបស់មនុស្សសុចរិតទាំងនោះឬទេ ?

**ពួកបរិសុទ្ធដែលអស្ចារ្យបំផុត ជាញឹកញាប់គឺជាអ្នកដែលទទួលអក្សរ ដ៏អស្ចារ្យ ។**

# ការទទួលអង្គរ របស់លោកម៉ូសេ

គំរូទីពីរសំរាប់អ្នកទូលអង្វររបស់យើងគឺ លោកម៉ូសេ។ **<u>និក្ខមនំ ៣២</u>** យើងបានឃើញថាលោកបានឡើងទៅលើភ្នំស៊ីណាយ ដើម្បីទទួលយកក្រឹត្តវិន័យរបស់ព្រះ បន្ទាប់ ពីលោកបាននៅលើភ្នំអស់រយះពេលជាច្រើនថ្ងៃ បណ្តាជនទាំងនោះបានត្រឡប់ជាគ្មានចិត្តអត់ធ្មត់ហើយបានបង្ខំអោយលោក អ៊ីរ៉ុន ធ្វើរូបព្រះអោយពួកគេគោរពបូជា ។ ដូច្នេះ អ៊ីរ៉ុន ក៏បានប្រមូលក្រវិលមាសរបស់ពួកគេមកធ្វើជារូបកូនគោមាស ហើយប្រជាជនអ៊ីស្រាអែលក៏ចាប់ផ្តើមនាំគ្នារាំជុំវិញរូបកូនគោមាសនោះ ហើយក៏នាំគ្នាគោរពបូជា ។ ព្រះទ្រង់ក៏ជ្រាប់ដឹងពីអ្វីដែលបានកើតឡើងនៅទីបោះជំរុំរបស់ជនជាតិអ៊ីស្រាអែល ទ្រង់មានបន្ទូលទៅកាន់ម៉ូសេ នៅលើកំពូលភ្នំ ដោយមានបន្ទូលថា ៖

« **៧.** ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ថា៖

ចូរចុះទៅ ដ្បិតពួកជននៃឯង ដែលឯងបាននាំចេញពីស្រុកអេស៊ីព្ទមក គេបានបង្ខូចចិត្តអស់ហើយ។ **៨.** ក៏រហ័សងាកបែរចេញពីផ្លូវដែលអញបានបង្គាប់គេ ហើយបានសិតធ្វើរូបកូនគោ នាំគ្នាក្រាបថ្វាយបង្គំដល់រូបនោះ

រួចបានថ្វាយយញ្ញបូជា ដោយប្រកាសថា នែ ពួកអ៊ីស្រាអែលអើយ នេះហើយជាព្រះនៃឯងដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក» ។ **និក្ខមនំ ៣២ : ៧ - ៨**

នៅពេលមានភាពតានតឹងនេះ ជាមួយវាសនានៃជនជាតិអ៊ីស្រាអែលដែលត្រូវបានព្យួរនៅក្នុតុល្យភាពមួយដែលត្រូវបានកំណត់ក្នុ ងការសន្ទនាជាលទ្ធផលរវាងព្រះជាម្ចាស់ និង លោកម៉ូសេ ។ ពួកអ៊ីស្រាអែលបាននិយាយទៅកាន់លោកម៉ូសេ ថា៖ ព្រះបានហៅពួកគេថា « ជារាស្រ្តរបស់អ្នក » ប៉ុន្តែ លោកម៉ូសេ មិនចង់ទទួលខុសត្រូវ ទៅលើបញ្ហាទាំងនេះទេ។ វាត្រូវបានឆ្លុះបញ្ចាំងមកលើព្រះវិញ ដែលថា៖

« ជារាស្រ្តរបស់ទ្រង់ » ពួកគេនៅតែបន្តការរាំជុំវិញរូបគោ ដោយមិនដឹងថាជោគវាសនារបស់ពួកគេកំពុងតែស្ថិតនៅលើការសន្ទនារវាងព្រះ និង លោកម៉ូសេឡើយ ព្រះបានប្រកាសប្រាប់ដល់ ម៉ូសេថា៖ **និក្ខមនំ ៣២៖១០**

« *ដូច្នេះទុកឲ្យអញឥឡូវចុះ ឲ្យសេចក្តីក្រោធរបស់អញបានឆេះក្តៅឡើងទាស់នឹងគេ អញនឹងបំផ្លាញគេឲ្យសូន្យទៅ ហើយនឹងបង្កើតនគរ១យ៉ាងធំពីឯងវិញ* »។

**<u>សូមចំណាំថា៖</u>**ព្រះនឹងមិនធ្វើអ្វីដល់ជនជាតិអ៊ីស្រាអែល

ទេ លុះត្រាតែ លោកម៉ូសេ យល់ព្រមដែរ ។ ប៉ុន្តែលោកម៉ូសេ មិនអាចអោយហេតុការនោះកើតឡើងទេ ។ គឺដូចជាអ្វីដែលអ្នកទូលអង្វរត្រូវធ្វើ គឺលោកជាអ្នកដែលឈររវាងព្រះ ហើយនឹងប្រជារាស្ត្រអ៊ីស្រាអែល ។ ទីបំផុតព្រះជាម្ចាស់បាននិយាយថា ទ្រង់នឹងប្រើលោកម៉ូសេ ដើម្បីប្រោសលោះសេចក្តីសន្យារបស់លោកអ័ប្រាហាំ, អ៊ីសាក និង លោកយ៉ាកុប ដោយការចាប់ផ្តើមទាំងអស់នៅលើលោកម៉ូសេ ហើយទ្រង់នឹងបង្កើតប្រជាជាតិមួយដ៏អស្ចារ្យពីរូបលោក ។ទោះជាពួកគេបានរស់ដោយមិនបានស្តាប់បង្គាប់ក៏ដោយ ពួកគេត្រូវបានក្លាយទៅជាបន្ទុករបស់លោកចាប់តាំងពីចេញពីស្រុកអេស៊ីបមក លោកម៉ូសេបានអង្វរសំរាប់ពួកគេ ។

**( ខ ១១ - ១២ )**ការព្រួយបារម្ភណ៍របស់លោកម៉ូសេនោះគឺសំរាប់កិត្តិសព្ទរបស់ព្រះ ។ លោកបាននិយាយថា «ឱព្រះអម្ចាស់អើយ ហេតុអ្វីបានជាទ្រង់មានសេចក្តីក្រោធក្តៅឡើងទាស់នឹងរាស្ត្រទ្រង់ ដែលទ្រង់បាននាំចេញពីស្រុកអេស៊ីព្ទមក ដោយព្រះចេស្តាដ៏ធំ ហើយដោយព្រះហស្តខ្លាំងពូកែដូច្នេះ **១២** ហេតុ អ្វីបានជាបើកឱកាសឲ្យសាសន៍អេស៊ីព្ទមានពាក្យដំណិះថា គឺព្រះចង់ធ្វើអាក្រក់ដល់គេហើយ បានជានាំគេចេញទៅ ដើម្បីនឹង

សំឡាប់នៅទីភ្នំ ហើយនឹងបំផ្លាញគេពីផែនដីចេញយ៉ាង នេះ »។

នៅក្នុងព្រះគម្ពីរ **និក្ខមនំ ៣២ : ៣០ - ៣២** យើងបានរកឃើញការដ៏ធំបំផុត អំពីការទូលអង្វររបស់លោកម៉ូសេ ។ បន្ទាប់ពីលោកបានវិលត្រលប់មកទីបោះជំរុំវិញ ហើយបានដឹងអំពីអ្វីដែលបានកើតឡើង លោកបាននិយាយទៅកាន់ប្រជារាស្ត្រអ៊ីស្រាអែលថា ៖

« **៣០**. *ដល់ថ្ងៃស្អែក ម៉ូសេក៏និយាយនឹងបណ្ដាជនទាំងឡាយថា ឯងរាល់គ្នាបានធ្វើបាបយ៉ាងធ្ងន់ណាស់ តែអញនឹងឡើងទៅឯព្រះយេហូវ៉ាឥឡូវ ប្រហែលជាអញនឹងធ្វើយ៉ាងណាឲ្យធួននឹងបាប ដើម្បីឲ្យឯងរាល់គ្នាបានរួច* **៣១** *.ដូច្នេះ ម៉ូសេត្រឡប់ទៅឯព្រះយេហូវ៉ាទូលថា បណ្ដាជននេះបានធ្វើបាបធ្ងន់ណាស់ហើយ គឺគេបានធ្វើព្រះពីមាសសំរាប់ខ្លួនគេ* **៣២**. *តែ ឥឡូវនេះសូមទ្រង់អត់ទោសចំពោះអំពើបាបរបស់គេផង ពុំនោះសោត សូមលុបឈ្មោះទូលបង្គំពីបញ្ជីដែលទ្រង់បានកត់ទុកចេញដែរ*»។

ហើយនេះគឺជាការទូលអង្វរ «ព្រះជាម្ចាស់អើយពួកគេសមនឹងទទួលនូវអ្វីដែលពួកគេសមនឹងទទួល សូមទ្រង់បានអត់ទោសអោយគេផង ប៉ុន្តែ បើមិនបាន សូមអោយការដាក់ទោសនេះធ្លាក់មកលើទូលបង្គំចុះ»។

*អ្នកទូលអង្វរជំនួសគឺជា ម្នាក់ដែលឈរនៅរវាងព្រះជាម្ចាស់ ហើយនឹងអ្វីដែលជាសេចក្តីក្រោធរបស់ទ្រង់។*

**ទំនុកតម្កើង ១០៦ : ១៩ - ២៣** បានផ្តល់ជូននូវការបង្ហាញយ៉ាងច្បាស់លាស់បំផុតអំពីហេតុការណ៍នេះ ៖

*១៩. គេបានធ្វើរូបកូនគោនៅត្រង់ភ្នំហោរែប ហើយបានក្រាបថ្វាយបង្គំចំពោះរូបសិតនោះ ២០. គឺយ៉ាងនោះដែលគេបានប្តូរព្រះដ៏ជាសិរីល្អនៃគេ ឲ្យបានជារូបដូចគោដែលស៊ីស្មៅវិញ ២១. គេបានភ្លេចព្រះដែលជួយសង្គ្រោះគេ ជាព្រះដែលបានធ្វើការយ៉ាងធំសំបើមនៅស្រុកអេស៊ីព្ទ ២២. គឺជាការយ៉ាងអស្ចារ្យនៅស្រុកហាំ និងការគួរស្ញែងខ្លាចនៅត្រង់សមុទ្រក្រហម ២៣. ដូច្នេះ ទ្រង់បានមានព្រះបន្ទូលថានឹងបំផ្លាញគេបង់ ប៉ុន្តែម៉ូសេ ជាអ្នករើសតាំងរបស់ទ្រង់ លោកបាន*

*ឈរនៅចំពោះទ្រង់ ក្នុងដំណើររំលងនោះ ដើម្បីនឹងបង្វែរសេចក្ដីក្រោធរបស់ទ្រង់ចេញ ក្រែងទ្រង់បំផ្លាញគេមែន។*

ម៉ូសេ បានឈរនៅក្នុងការរំលងដែលបានធ្វើឡើងដោយអំពើបាបរបស់ប្រជារាស្ត្ររបស់ព្រះ លោកបាននិយាយថា « ព្រះជាម្ចាស់អើយ! ខ្ញុំកំពុងតែបញ្ឈប់នូវចន្លោះនេះ » ការខកព្រះហឫទ័យរបស់ទ្រង់មិនអាចធ្លាក់មកលើពួកគេឡើយ លុះត្រាវាបានធ្លាក់មកលើខ្ញុំជាមុនសិន ។ នៅក្នុងព្រះគម្ពីរ **<u>ជនគណនា ១៦</u>** បានកំណត់ត្រាទុក អំពីគំរូផ្សេងៗទៀត អំពីការទូលអង្វរ ។ នៅទីនេះគឺជា ការទូលអង្វររបស់ ម៉ូសេ និង អើរ៉ុន។ ព្រះជាម្ចាស់មានអធិបតេយ្យភាពដែលបានដោះស្រាយជាមួយនឹងការប៉ះបោររបស់ពួកកូរេ ពួកដាថាន និង អ័ប៊ីរ៉ាមដោយធ្វើឱ្យដីប្រេះបើកឡើងដើម្បីនិងលេបពួកគេទាំងរស់។ **៤១.** លុះដល់ថ្ងៃស្អែកឡើង ពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់គ្នា ក៏រអ៊ូរទាំទាស់នឹងម៉ូសេ ហើយនឹងអើរ៉ុនថា លោកបានសំឡាប់ពួកជននៃព្រះយេហូវ៉ា **៤២.** កាលពួកជំនុំបានប្រជុំគ្នាទាស់នឹងម៉ូសេ ហើយនឹងអើរ៉ុនដូច្នេះ នោះគេក្រឡេកមើលទៅខាងត្រសាលជំនុំ

ឃើញពពកមកគ្របលើត្រសាល ហើយសិរីល្អនៃព្រះយេហូវ៉ាក៏លេចមកដែរ **៤៣.** ឯម៉ូសេ និងអើរ៉ុនក៏ទៅឯត្រង់មុខត្រសាលជំនុំជួបនឹងព្រះ **៤៤.** នោះព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា **៤៥.** ចូរ ឲ្យឯងថយចេញពីពួកជំនុំនេះទៅ ដើម្បីឲ្យអញបានបំផ្លាញគេចេញជាមួយរំពេច តែអ្នកទាំងពីរក៏ទំលាក់ខ្លួនចុះក្រាបផ្កាប់មុខ។

គោលជំហររបស់អ្នកទូលអង្វរ គឺត្រូវឱនមុខក្រាបចុះនៅចំពោះព្រះជាម្ចាស់ ដោយដឹងថាការវិនិច្ឆ័យនោះគឺជាអំពើនៃការធ្លាក់ចុះ ។

ចំពោះខ្លួនខ្ញុំ ខ្ញុំស្ញប់ស្ញែងចំពោះសរគុណរបស់លោកម៉ូសេ និងលោកអើរ៉ុន ប្រជារាស្ត្រទាំងអស់នោះបានត្រឡប់ជាប្រឆាំង ជាមួយពួកគាត់ដោយមិនមានហេតុផង។ មិនតែប៉ុណ្ណោះពួកលោកមិនបានប្រកាន់ទោសចំពោះពួកជនទាំងនោះឡើយ ថែមទាំងមានឆន្ទះក្នុងការជួយអង្វរជំនួសពួកគេទៀត សូម្បីតែត្រូវប្រថុយជីវិតខ្លួនឯងក៏ដោយ ។

លោកម៉ូសេបាននិយាយទៅកាន់លោកអើរ៉ុន ហើយបានប្រាប់ពីអ្វីដែលលោកត្រូវធ្វើសំរាប់ជនជាតិអ៊ីស្រាអែល ។

«**៤៦.** ចូរយកពានរបស់បងទៅ ហើយយកភ្លើងពីលើ អាសនាមកដាក់ រួចរោយកំញាន នាំយកទៅឯពួកជំនុំ ថ្វាយឲ្យធួននឹងគេ**ជាប្រញាប់ទៅ** «

*គោលជំហររបស់អ្នកទូលអង្វរគឺត្រូវឱនមុខក្រាប ចុះនៅចំពោះព្រះ*

ដ្បិតមានសេចក្តីក្រោធចេញពីចំពោះព្រះយេហូវ៉ា មក មានមនុស្សកំពុងតែដួលស្លាប់ហើយ។ **៤៧.** ដូច្នេះ អើរ៉ុនក៏យកពានទៅតាមបង្គាប់ម៉ូសេ ហើយ រត់ទៅឯកណ្តាលពួកជំនុំ នោះឃើញមនុស្សកំពុងតែ ដួលស្លាប់នៅក្នុងពួកគេហើយ រួចលោករោយកំញាន ថ្វាយឲ្យធួននឹងគេ **៤៨.** ក៏ឈរនៅកណ្តាលពួកមនុស្ស ស្លាប់ និងពួកមនុស្សរស់ ដូច្នេះការប្រហារជីវិតនោះក៏ បាត់ទៅ » ។ **ជនគណនា ១៦ : ៤៦ - ៤៨** ភាសាដែល ត្រូវប្រើនៅក្នុងអត្ថបទនេះសង្កត់ធ្ងន់ទៅលើពាក្យថា « **បន្ទាន់** សំរាប់ការទូលអង្វរ »( **Urgency** to intercession )លោកម៉ូសេបាននិយាយទៅកាន់លោកអើរ៉ុនថា « **ទៅ អោយលឿន** » ( **Go quickly** ) អើរ៉ុនមិនបាន **ដើរ** ទេ គឺ គាត់បាន **រត់** រាល់ការចំណាយពេលនោះគឺមានតំលៃសំ រាប់ជីវិត ។ ពាក្យថា «គ្រោះកាច»វាគឺជាជំងឺឆ្លង ដែល

ត្រូវការ ការប្រោះលោះ លោកអើរ៉ុនបានបង្ហាញពីការប្រឈមមុខរបស់គាត់ ទៅនឹងការឆ្លងរាលដាលនេះ។ គឺលោក បានប្រថុយជីវិតរបស់លោកខណៈពេលដែលគាត់បានចាក់ចេញពីភាជន៍នោះ ផ្សែងបានកើតឡើងជាខ្សែបន្ទាត់ពណ៌សដែលបែងចែករវាងមនុស្សរស់ និង ពួកអ្នកស្លាប់ ។ កន្លែងណាដែលភាជន៍នោះបញ្ចេញផ្សែងទៅដល់សេចក្តីក្រោធក៏ត្រូវបានបញ្ចប់ ។

**នេះជាអ្វីដែលជាការទូលអង្វរ ការចូលមកដល់ការប្រថុយជីវិតរបស់អ្នក រវាងសេចក្តីស្លាប់ ហើយនឹងអ្នកដែលត្រូវស្លាប់នោះ សូមថ្វាយពាក្យអធិស្ឋានដ៏ក្លៀវក្លា និង ពាក្យទូលអង្វរ នឹងបានដូចជាផ្សែងពណ៌សដែលហូរចេញមករហូតដល់សេចក្តីក្រោធត្រូវបានបញ្ឈប់ ។**

## *កង្វះនៃអ្នកទូលអង្វរ*

**<u>អេសេគាល ២២ : ២៣ - ៣១</u>** កំណាត់គ្រានៅក្នុងព្រះគម្ពីរដែលមានហេតុការណ៍កើតឡើង ផ្សេងៗគ្នានោះ មានព្រឹត្តិការមួយចុងក្រោយ ដែលពិពណ៌នាអំពីអំពើរបាបរបស់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ។

វាមានភាពខុសគ្នានៅត្រង់កន្លែងនេះ គឺយើងមិនបាន

ឃើញមានអ្នកទទួលអង្វររវាងអំពើរបាបរបស់មនុស្ស និងការវិនិច្ឆ័យរបស់ព្រះនោះទេ ។

**២៣.** ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា **២៤.** កូនមនុស្សអើយ ចូរប្រាប់ដល់ទីក្រុងថា ឯងជាស្រុកដែលមិនបានជំរះសំអាតឡើយ ក៏គ្មានភ្លៀងធ្លាក់មកលើឯងក្នុងគ្រានៃសេចក្តីគ្នាន់ក្នាញ់ផង **២៥.** ពួក ហោរារបស់វាគេគិតគូរគ្នានៅកណ្តាលនោះ ហាក់ដូចជាសិង្ហ ដែលគ្រហឹមកំពុងហែករំពាស៊ី គេបានត្របាក់លេបព្រលឹងមនុស្ស គេយកទ្រព្យសម្បត្តិ និងរបស់មានដំឡៃទៅ ហើយគេធ្វើឲ្យមានពួកស្រីមេម៉ាយជាច្រើននៅកណ្តាលទីក្រុង **២៦.** ពួក សង្ឃក៏បានធ្វើទទឹងនឹងក្រឹត្យវិន័យរបស់អញ ព្រមទាំងបង្អាប់របស់បរិសុទ្ធទាំងប៉ុន្មានរបស់អញ គេមិនបានចេះញែករបស់បរិសុទ្ធចេញពីរបស់ធម្មតាទេ ក៏មិនបានបង្ហាញឲ្យមនុស្សចេះសំគាល់របស់មិនស្អាត និងរបស់ស្អាតដែរ គេគេចភ្នែកចេញពីថ្ងៃឈប់សំរាករបស់អញ ហើយអញក៏ត្រូវអាប់ឱននៅក្នុងពួកគេ **២៧.** ពួក ចៅហ្វាយនៅកណ្តាលទីក្រុងប្រព្រឹត្តដូចជាសត្វស្វាន ដែលកំពុងហែករំពា គេប្រព្រឹត្តដូច្នោះ ដើម្បីនឹងកំចាយឈាម ហើយបំផ្លាញព្រលឹងមនុស្ស ប្រយោជន៍ឲ្យបានកំរៃទុច្ចរិត **២៨.** ពួក ហោរាបានបូក

ល្បាប់ឲ្យគេ ដោយឃើញការជាក់ស្តែងជាសេចក្ដីកំភូត ហើយទាយកុហកដល់គេថា ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានព្រះបន្ទូលដូច្នេះ ក្នុងកាលដែលព្រះយេហូវ៉ាមិនបានមានព្រះបន្ទូលសោះ **២៩.** ពួក ជននៅស្រុកធ្លាប់សង្កត់សង្កិន ហើយប្លន់ អើ គេបៀតបៀនមនុស្សក្រីក្រ និងពួកកំសត់ទុគ៌ត ហើយបានសង្កត់សង្កិនមនុស្ស ដែលស្នាក់នៅ ដោយឥតហេតុ **៣០. អញបានស្វែងរកមនុស្សម្នាក់ក្នុងពួកគេ ដែលនឹងសង់កំផែងឡើង ហើយឈរនៅចន្លោះបាក់បែកនៅមុខអញជំនួសគេ ដើម្បីឲ្យអញមិនបំផ្លាញស្រុកគេឡើយ ប៉ុន្តែអញរកមិនបានអ្នកណាមួយសោះ ៣១.** ហេតុ នោះបានជាអញចាក់សេចក្ដីគ្នាន់ក្នាញ់របស់អញទៅលើគេ។

គ្រប់ផ្នែកទាំងអស់នៃប្រជាជនទាំងនោះបានបរាជ័យទាំងស្រុង ទាំងពួកហោរា ពួកសង្ឃ ពួកមេដឹកនាំ និង ប្រជាជនដែលនៅទីនោះ។

គ្រប់គ្នាដែលមាននៅទីនេះគឺជាធាតុផ្សំយ៉ាងជាក់លាក់នៅក្នុងសង្គម ។

- ពួកហោរា គឺជាអ្នកដែលមានតួនាទីនាំយកព្រះរាជសារដោយផ្ទាល់មកពីព្រះជាម្ចាស់។
- ពួកសង្ឃ គឺជាមេដឹកនាំនៃស្ថាប័នខាងសាសនា

- ពួកមេដឹកនាំ គឺជាអ្នកគ្រប់គ្រងប្រទេស
- ប្រជាជន គឺជាប្រជាជនដែលរស់នៅសាមញ្ញ

កត្តាផ្សំសំរាប់ក្រុមមនុស្សទាំង បួន ប្រភេទខាងលើនេះ គឺមានសារះសំខាន់ណាស់សំរាប់ប្រទេសមួយ ។ ដំណើរការនៃការពុកផុយ បានចាប់ផ្តើមជាមួយនឹងថ្នាក់ដឹកនាំខាងវិញ្ញាណ នោះរដ្ឋាភិបាលខាងលោកិយត្រូវបានខូច នៅទីបំផុតប្រជាជាតិទាំងមូលត្រូវទទួលរងផលប៉ះពាល់ ។ (វាបានកើតមាននៅប្រទេសអាមេរិកសម័យទំនើប និងនៅប្រជាជាតិផ្សេងៗមួយចំនួនដែរ)។

បើទោះបីជាគ្រប់ផ្នែកនៃសង្គមត្រូវបានធ្វើអោយខូច បើស្ថិតក្នុងស្ថានភាពបែបនោះ វាមិនទាន់អស់ក្តីសង្ឃឹមនៅឡើយទេ ។ ព្រះទ្រង់នឹងស្វែងរកមនុស្សម្នាក់ ជាអ្នកទូលអង្វរជំនួសអោយក្រោកឈរនៅចន្លោះ ហើយធ្វើអោយមានរបង សំរាប់ការពារប្រជាជាតិទាំងមូលបាន។ ប៉ុន្តែ ដោយព្រោះតែទ្រង់មិនអាចរកឃើញម្នាក់សោះ នោះទ្រង់ក៏ចាក់សេចក្តីខ្ញាល់របស់ទ្រង់ទៅលើពួកគេ ៖

**« អញបានរំលីងគេ ដោយភ្លើងនៃសេចក្តីក្រោធ»**

*មនុស្សម្នាក់ អ្នកទូលអង្វរម្នាក់ អាចសង្គ្រោះប្រជាជាតិទាំងមូលពីការជំនុំជំរះរបស់ព្រះបាន ។*

# តម្រូវការចាំបាច់សម្រាប់អ្នកទូលអង្វរ

ព្រះគម្ពីរបានបើកសំដែងថា ការជំនុំជំរះគឺអាស្រ័យទៅលើពន្លឺដែលបានផ្តល់មក។ នៅពេលដែលយើងពិចារណាលើប្រព័ន្ធផ្សព្វផ្សាយ ដែលសេចក្តីពិតនេះកំពុងបានរីកពាលដាល នៅថ្ងៃនេះដូចជាតាមរយៈទូរទស្សន៍ ,វិទ្យុ, សៀវភៅ, ប្រព័ន្ធ ផ្សព្វផ្សាយឌីជីថលផ្សេងៗ ខ្ញុំអាចនិយាយបានថានឹងមិនធ្លាប់មានជំនាន់ណា ធ្លាប់មានពន្លឺខាងវិញ្ញាណដែលអាចយកប្រើប្រាស់បានយ៉ាងច្រើន ជាងពេលបច្ចុប្បន្ននេះទេ។

ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំជាសំឡេងនៅក្នុងឆ្នាំ **១៩៥៣** នៅពេលដែលខ្ញុំកំពុងតែធ្វើជាគ្រូគង្វាលនៅប្រទេសអង់គ្លេស ទ្រង់បានមានបន្ទូថា ៖

នឹងមានការរស់ឡើងវិញដ៏អស្ចារ្យមួយ នៅក្នុងសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស សម្រាប់ការនេះ ព្រះបានដាក់ចុះតម្រូវការជាមូលដ្ឋានមួយនោះគឺ**ការស្តាប់បង្គាប់** ខ្ញុំជឿជាក់ថា ការរស់ឡើងវិញដ៏អស្ចារ្យនោះវានឹងមកប្រសិនបើ ព្រះជាម្ចាស់ទ្រង់អាចរកឃើញអ្នកទូលអង្វរ

មកឈរនៅចំពោះការវិនិច្ឆ័យរបស់ទ្រង់ហើយស្រែក ហៅរកសេចក្ដីមេត្តាករុណារបស់ព្រះ ។

នៅចុងបញ្ចប់នៃមេរៀននេះសូមអនុញ្ញាត្តិអោយខ្ញុំអោយនូវសេចក្ដីថ្លែងការ ៤ យ៉ាងដែលខ្ញុំបានមើលឃើញក្នុងគ្រប់ទាំងអ្នកទទួលអង្វរដ៏ពិត។

<u>**ទី ១៖**</u> អ្នកទូលអង្វរម្នាក់ដូចជាលោក អ័ប្រាហាំ គឺការផ្ដន្ទាទោស គឺត្រូវតែមាននៅក្នុងសេចក្ដីសុចរិតរបស់ព្រះ ដែលទ្រង់មិនដែលនាំយកការវិនិច្ឆ័យមកលើមនុស្សសុចរិតជាមួយនឹងមនុស្សអាក្រក់នោះទេ។ នៅពេលជាមួយគ្នានេះដែរ ទ្រង់មានសុភ័ក្តវិនិច្ឆ័យច្បាស់លាស់ ក្នុងការស្វែងរកយុត្តិធម៌យ៉ាងពេញលេញ ហើយមនុស្សអាក្រក់មិនដែលគេចផុតពីការជំនុំជំរះរបស់ទ្រង់ឡើយ ។

<u>**ទី ២៖**</u> ជាអ្នកដែលពេញទៅដោយការព្រួយបារម្ភណ៍ចំពោះការថ្វាយសិរីរុងរឿងដល់ព្រះ។

គឺដូចជាលោកម៉ូសេ ជាអ្នកដែលបានបដិសេធន៍ពីរដងនូវការផ្ដល់ជូនរបស់ព្រះដើម្បីអោយគាត់ក្លាយទៅជាបុព្វបុរសរបស់ប្រជាជាតិដ៏ធំបំផុតនៅលើផែនដី។

ការថ្វាយសិរីរុងរឿងដល់ព្រះ នោះវាសំខាន់ជាងការទទួលបានកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួនរបស់គាត់។

**ទី ៣៖** អ្នកទូលអង្វរ គឺត្រូវតែមានភាពជិតស្និទ្ធជាមួយនឹងព្រះ ។

គឺជាអ្នកដែលបានរៀបចំខ្លួនជាស្រេចដើម្បីប្រថុយជីវិតរបស់ខ្លួនផ្ទាល់ ដូចជាលោកអើរ៉ុនដែលមិនបានអើពើរនូវការរីករាលដាលនៃជំងឺអាសន្នរោគ ដោយយកខ្លួនរបស់គាត់ឈរនៅត្រង់ទី រវាងមនុស្សស្លាប់ និងមនុស្សរស់ ។

**ទី ៤** ជាចំណុចចុងក្រោយ ៖ អ្នកទូលអង្វរ គឺត្រូវតែជាអ្នកដែលពោរពេញដោយភាពក្លាហាន។ គឺជាអ្នកដែលហានប្រថុយជីវិតរបស់ខ្លួន ដូចជាលោកអ៊ីរ៉ុន ហើយនិយាយថា « ខ្ញុំនឹងរត់ទៅឈរនៅទីនោះ បើទោះជាត្រូវប្រថុយជីវិតដល់ស្លាប់ ជាមួយនឹងជំងឺអាសន្នរោគនោះក៏ដោយ » ។ គ្មានការត្រាស់ហៅណាដែលខ្ពស់ជាង ការត្រាស់ហៅអោយមកធ្វើជាអ្នកទូលអង្វរនោះទេ ។

នៅពេលដែលយើងបានក្លាយទៅជាអ្នកទូលអង្វរ នោះគឺថា យើងបានឈានដល់ចំពោះមុខបល្ល័ង្កនៃព្រះ ។

មនុស្សនឹងមិនឃើញអ្នកដោយភ្នែក ប៉ុន្តែនៅក្នុងនគររបស់ព្រះជីវិតរបស់អ្នកនឹងត្រូវបានរាប់ជាពេលវេលមួយដ៏នៅអស់កល្ប ។

ប្រែសម្រួលជាភាសាខ្មែរដោយ

**អង្គការមួយសម្រាប់មួយកម្ពុជា**

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកការិយាល័យ យើងខ្ញុំតាមរយៈអាសយដ្ឋាន: ផ្ទះលេខ៣៨-៣៨ អា ផ្លូវ៣៣៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ទូរស័ព្ទលេខ: ០២៣ ៦៧ ៥៥៥ ៨៦

គេហទំព័រ: www.one2oneword.org

# អង្គការមួយសម្រាប់មួយកម្ពុជា

បានទទួលសិទ្ធិ

ក្នុងការប្រែសម្រួលទៅជាភាសាខ្មែរ

នៅក្នុងការិយាល័យព័ន្ធកិច្ចដេរេកព្រីនស៍

(Derek Prince)

ប្រចាំនៅប្រទេសកម្ពុជា តាមរយៈ

ព័ន្ធកិច្ចដេរេកព្រីនស៍ប្រចាំនៅតំបន់អាស៊ី-ប៉ាស៊ីភិច

ទំនាក់ទំនងអាសយដ្ឋាន ផ្លូវហដុន៣៨

ប្រអប់សំបុត្រ ២០២៩

ព្រះវិហារព្រះគ្រិស្ត ៨១៤០

ប្រទេសណូវ៉ែលសេឡង់

ទូរស័ព្ទលេខ : ០០៦៤ ៣ ៣៦៦ ៤៤៤៣

ទូរសារ : ០០៦៤  ៣ ៣៦៦ ១៥៦៩

អ៊ីម៉ែល admin@dpm.co.nz

គេហទំព័រ www.dpm.co.nz